**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៩៥៨......សហវ...ប្រក.អគគ

# ប្រកាស
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការដំឡើងសាខាគយនិងរដ្ឋាករចំនួន ២ ទៅជានាយកដ្ឋានស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសលេខ១៦៣ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

សេវាសាធារណៈដែលផ្តល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពនៃសេវា ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសនេះ។

**ប្រការ២ .-**

ត្រូវបាននិរាករណ៍ប្រកាសលេខ១៦០៨ សហវ.ប្រក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជាអគ្គនាយក ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងគ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ។

ថ្ងៃព្រហស្បតិ៍ ២កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ [illegible] សហវ.ប្រក [illegible] ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២៣

## ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| លេខរៀងសេវា | បរិយាយសេវា | តម្លៃឯកតានៃសេវា (គិតជារៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព/ផ្សេងៗ |
|---|---|---|---|---|
| ១ | ប្រឹក្សាអំពីនីតិវិធីគយ | ឥតគិតថ្លៃ | ភ្លាមៗ | |
| ២ | លិខិតអនុញ្ញាតគយ (ក្នុងមួយឯកសារ) | ឥតគិតថ្លៃ | ២ថ្ងៃ | ៣០ថ្ងៃ |
| ៣ | ផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ (ក្នុងមួយឯកសារ) | ឥតគិតថ្លៃ | ២ថ្ងៃ | ៤៥ថ្ងៃ |
| ៤ | ផ្ទៀងផ្ទាត់សំអាងដើមកំណើតទំនិញ (ក្នុងមួយឯកសារ) | ឥតគិតថ្លៃ | ២ថ្ងៃ | ៤៥ថ្ងៃ |
| ៥ | វិធានបញ្ជាក់ជាមុន (ក្នុងមួយឯកសារ) | ២០០ ០០០ | ៣០ថ្ងៃ | ៣ឆ្នាំ |
| ៦ | ចុះបញ្ជីធុរជនក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យ (ក្នុងមួយឯកសារ) | ឥតគិតថ្លៃ | ភ្លាមៗ | |
| ៧ | កែតម្រូវ ឬធ្វើទុតិយតាបង្កាន់ដៃពន្ធទោចក្រយានយន្ត (ក្នុងមួយគ្រឿង) | ឥតគិតថ្លៃ | ២ថ្ងៃ | |
| ៨ | កែតម្រូវ ឬធ្វើទុតិយតាបង្កាន់ដៃពន្ធ និងលតាបត្ររថយន្តនិងគ្រឿងចក្រ (ក្នុងមួយគ្រឿង) | ២០០ ០០០ | ២ថ្ងៃ | |
| ៩ | តែមប្រើអាករសម្រាប់បិទលើកញ្ចប់បារី (ក្នុងមួយសន្លឹក) | ៥០ | ភ្លាមៗ | |
| ១០ | ត្រាពន្ធគយ (ក្នុងមួយសន្លឹក) | ១០០ | ភ្លាមៗ | |
| ១១ | លិខិតអនុញ្ញាតដឹកជញ្ជូន ឬស្តុក (ក្នុងមួយសន្លឹក) | ១ ០០០ | ភ្លាមៗ | |
| ១២ | បណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូន (ក្នុងមួយបណ្ណ) | ៥ ០០០ | ២ថ្ងៃ | ១ឆ្នាំ |
| ១៣ | សៀវភៅកុងតឺន័រ (ក្នុងមួយគ្រាប់) | ៨ ០០០ | ភ្លាមៗ | |
| ១៤ | លតាប័ត្ររថយន្ត (ក្នុងមួយលេខ) | ៦០ ០០០ | ភ្លាមៗ | |

| លេខរៀងសេវា | បរិយាយសេវា | តម្លៃឯកតានៃសេវា (គិតជារៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព /ផ្សេងៗ |
|---|---|---|---|---|
| | បែបបទតយ÷ | | | |
| ១៥ | - មួយប្រតិវេទន៍តយទំនិញដែលមានតម្លៃគិតពន្ធគយ ក្រោម ១ ០០០ ដុល្លារអាម៉េរិក | ឥតគិតថ្លៃ | ភ្លាមៗ | |
| ១៦ | - មួយប្រតិវេទន៍គយទំនិញដែលមានតម្លៃគិតពន្ធគយ ចាប់ពី ១ ០០០ ដុល្លារអាម៉េរិកឡើង ផ្ទុកក្នុងកុងតឺន័រតែមួយ មានច្រើនម្ចាស់ | ៤០ ០០០ | ភ្លាមៗ | |
| ១៧ | - មួយប្រតិវេទន៍គយទំនិញដែលមានតម្លៃគិតពន្ធគយ ចាប់ពី ១ ០០០ ដុល្លារអាម៉េរិកឡើង មិនផ្ទុកក្នុងកុងតឺន័រ ឬផ្ទុកក្នុងកុងតឺន័រតូចជាង ២០ហ្វីត | ៤០ ០០០ | ភ្លាមៗ | |
| ១៨ | - មួយកុងតឺន័រចាប់ពី ២០ហ្វីតឡើង ចំពោះប្រតិវេទន៍គយទំនិញដែលមានតម្លៃគិតពន្ធគយ ចាប់ពី ១ ០០០ ដុល្លារអាម៉េរិកឡើង | ៦០ ០០០ | ភ្លាមៗ | |
| ១៩ | - មួយប្រតិវេទន៍គយផលិតផលតេលសិលា ជាប្រេងសាំង ប្រេងសាំងយន្តហោះ ប្រេងម៉ាស៊ូត ប្រេងកាត ប្រេងខ្មៅ ឧស្ម័ន ឬសារធាតុគីមី MTBE | ២០០ ០០០ | ភ្លាមៗ | |
| | ចុះបញ្ជិកាប្រតិវេទន៍គយ÷ | | | |
| ២០ | - មួយប្រតិវេទន៍គយទំនិញនាំចេញ នាំចូល ដែលមានតម្លៃគិតពន្ធគយក្រោម ១ ០០០ ដុល្លារអាម៉េរិក (ប្រតិវេទន៍គយបំព្រួញ) | ៨ ០០០ | ភ្លាមៗ | |
| ២១ | - មួយប្រតិវេទន៍គយទំនិញនាំចេញ នាំចូល ដែលមានតម្លៃគិតពន្ធគយចាប់ពី ១ ០០០ ដុល្លារអាម៉េរិកឡើង (ឯកសាររដ្ឋបាលតែមួយ) | ១៥ ០០០ | ភ្លាមៗ | |
| ២២ | - មួយប្រតិវេទន៍គយទំនិញឆ្លងកាត់ | ១៥ ០០០ | ភ្លាមៗ | |
| | ត្រួតពិនិត្យកុងតឺន័រដោយម៉ាស៊ីនស្កែន÷ | | | |
| ២៣ | - មួយកុងតឺន័រក្រោម ៤០ហ្វីត | ៤០ ០០០ | ភ្លាមៗ | |
| ២៤ | - មួយកុងតឺន័រចាប់ពី ៤០ហ្វីតឡើង | ៦៤ ០០០ | ភ្លាមៗ | |

| លេខរៀងសេវា | បរិយាយសេវា | តម្លៃឯកតានៃសេវា (គិតជារៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព/ផ្សេងៗ |
|---|---|---|---|---|
| | ការងារក្រៅការិយាល័យគយ÷ | | | |
| ២៥ | - ត្រួតពិនិត្យទំនិញផ្ទុកក្នុងកុងតឺន័រ ក្នុងម៉ោងធ្វើការ (ក្នុងមួយកុងតឺន័រ) | ១០ ០០០ | ភ្លាមៗ | |
| ២៦ | - ត្រួតពិនិត្យទំនិញផ្ទុកក្នុងកុងតឺន័រ ក្រៅម៉ោងធ្វើការ (ក្នុងមួយកុងតឺន័រ) | ២០ ០០០ | ភ្លាមៗ | |
| ២៧ | - ត្រួតពិនិត្យទំនិញមិនផ្ទុកក្នុងកុងតឺន័រ ក្នុងម៉ោងធ្វើការ (ក្នុងមួយប្រតិវេទន៍) | ៤០ ០០០ | ភ្លាមៗ | |
| ២៨ | - ត្រួតពិនិត្យទំនិញមិនផ្ទុកក្នុងកុងតឺន័រ ក្រៅម៉ោងធ្វើការ (ក្នុងមួយប្រតិវេទន៍) | ៨០ ០០០ | ភ្លាមៗ | |
| ២៩ | - អមទំនិញ [១] (ក្នុងមួយនាក់ ក្នុងមួយថ្ងៃ) | ១០០ ០០០ | ភ្លាមៗ | |
| ៣០ | ធ្វើការបន្ថែមម៉ោងពេលយប់ ចាប់ពីម៉ោង ១៨:០០ល្ងាច ដល់ម៉ោង ០៧:០០ព្រឹក នៅតាមបណ្តាផែស្ងួត សម្រាប់ការងារនាំចេញ (ក្នុងមួយនាក់ ក្នុងមួយម៉ោង) | ២០ ០០០ | ភ្លាមៗ | |
| ៣១ | សិទ្ធិប្រឡង និងសិក្សាវគ្គជើងសាគយ | ១ ០០០ ០០០ | ភ្លាមៗ | |
| ៣២ | អាជ្ញាបណ្ណជើងសាគយ (ក្នុងមួយអាជ្ញាបណ្ណ) | ៤ ០០០ ០០០ | - ៣០ថ្ងៃ (ស្នើសុំថ្មី)<br>- ២ថ្ងៃ (បន្តសុពលភាព) | ២ឆ្នាំ |
| ៣៣ | អាជ្ញាបណ្ណភណ្ឌាគារគយមានដែនកំណត់ ឬ សន្និធិគយបណ្តោះអាសន្ន (ក្នុងមួយអាជ្ញាបណ្ណ) | ១០ ០០០ ០០០ | - ៤៥ថ្ងៃ (ស្នើសុំថ្មី) [២]<br>- ២ថ្ងៃ (បន្តសុពលភាព) | ៣ឆ្នាំ ឬតាមការសម្រេចជាក់ស្តែង |
| ៣៤ | ការគ្រប់គ្រងប្រតិបត្តិការភណ្ឌាគារគយមានដែនកំណត់ | ១%នៃប្រាក់ពន្ធនិងអាករមធ្យមប្រចាំខែដែលត្រូវជាប់លើទំនិញក្នុងភណ្ឌាគារ ឬយ៉ាងតិច ២ ០០០ ០០០ | ភ្លាមៗ | ១ឆ្នាំ |
| ៣៥ | ការគ្រប់គ្រងប្រតិបត្តិការសន្និធិគយបណ្តោះអាសន្ន | ២០ ០០០ ០០០ | ភ្លាមៗ | ១ឆ្នាំ |

| លេខរៀងសេវា | បរិយាយសេវា | តម្លៃឯកតានៃសេវា (គិតជារៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព/ផ្សេងៗ |
|---|---|---|---|---|
| | **ការគ្រប់គ្រងការឆ្លងកាត់អន្តរជាតិ** (៣) ÷ | | | |
| ៣៦ | - ទំនិញមួយកុងតឺន័រតូចជាងឬស្មើ ២០ហ្វីត | ៤០០ ០០០ | ភ្លាមៗ | |
| ៣៧ | - ទំនិញមួយកុងតឺន័រលើសពី ២០ហ្វីត | ៤៨០ ០០០ | ភ្លាមៗ | |
| ៣៨ | - ទំនិញមិនផ្ទុកក្នុងកុងតឺន័រ (ក្នុងមួយរថយន្ត ឬមធ្យោបាយដឹកជញ្ជូន) | ៤៨០ ០០០ | ភ្លាមៗ | |
| ៣៩ | - គោ ក្របី និងសេះរស់ (ក្នុងមួយក្បាល) | ៤០ ០០០ | ភ្លាមៗ | |
| ៤០ | - ជ្រូក ចៀម និងពពែរស់ (ក្នុងមួយក្បាល) | ១០ ០០០ | ភ្លាមៗ | |
| ៤១ | - សត្វស្លាប (មាន់ ទា ...) (ក្នុងមួយគីឡូក្រាម) | ១ ០០០ | ភ្លាមៗ | |
| ៤២ | - ផលិតផលជលផល (ក្នុងមួយគីឡូក្រាម) | ១ ០០០ | ភ្លាមៗ | |

**កំណត់សម្គាល់÷**

(១) មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចអមទំនិញ ត្រូវមានចំនួនសមស្រប ដោយយ៉ាងតិចមានចំនួន ២នាក់

(២) រយៈពេលផ្តល់សេវាដែលចែងក្នុងតារាងខាងលើនេះ គឺអនុវត្តចំពោះការស្នើសុំដែលមានសំណុំឯកសារគ្រប់គ្រាន់ និងបានបំពេញគ្រប់លក្ខខណ្ឌតម្រូវ

(៣) ពាក្យ "កុងតឺន័រ" រាប់បញ្ចូលទាំងកុងតឺន័រភ្ជាប់នឹងរថយន្តស្រាប់ ដែលមិនអាចស្ទូចផ្ទេរចុះឡើងបាន។